# ដង្វាយធួនរបស់ព្រះអង្គសង្គ្រោះ

ឯកសារថ្នាក់សិក្ខាសាលាសម្រាប់ព្រះគម្ពីរសញ្ញាថ្មី

វគ្គបទគម្ពីរ និងសេចក្ដីថ្លែងការណ៍ខាងក្រោមនេះបង្រៀនអំពីដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ ។ សូមចំណាយពេល ១០ ទៅ ១៥ នាទីអានប្រភពទាំងនេះដោយយកចិត្តទុកដាក់ ( ឬប្រភពផ្សេងទៀតអំពីដង្វាយធួនរបស់ព្រះអង្គសង្គ្រោះ ដែលអ្នកចាប់អារម្មណ៍ចង់រៀនសូត្រ ឬដែលអ្នកបានរកឃើញមុនមេរៀននេះ ) ។ ពេលអ្នកអាន សូមគិតអំពីរបៀបដែលប្រភពនីមួយៗ ជួយអ្នកឲ្យយល់កាន់តែច្បាស់អំពីអ្វីដែលព្រះវរបិតាសួគ៌ និងព្រះយេស៊ូវគ្រីស្ទបានធ្វើសម្រាប់អ្នក និងមូលហេតុនៃការធ្វើដូច្នោះ ។

- លូកា ២២:៣៩–៤៤
- លូកា ២៣:៣៣–៣៨, ៤៤–៤៦
- យ៉ូហាន ៣:១៤–១៧
- អាលម៉ា ៧:១១–១៣
- នីហ្វៃទី៣ ២៧:១៤
- គោលលទ្ធិ និង សេចក្ដីសញ្ញា ១៨:១០–១១
- គោលលទ្ធិ និង សេចក្ដីសញ្ញា ១៩:១៦–១៩

អែលឌើរ ថាត អរ ខាលីស្ទើរ ក្នុងពួកចិតសិបនាក់បានបង្រៀន ៖



ដូច្នេះតើដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទគឺជាអ្វី ? ក្នុងន័យមួយ វាគឺជាបណ្ដុំព្រឹត្តិការណ៍ដ៏ទេវភាពដែលបានចាប់ផ្ដើមនៅក្នុងសួនច្បារគែតសេម៉ានី បានបន្តនៅលើឈើឆ្កាង ហើយបានបញ្ចប់ជាមួយនឹងការមានព្រះជន្មរស់ឡើងវិញរបស់ព្រះអង្គសង្គ្រោះចេញពីផ្នូរ ។ វាត្រូវបានជំរុញចិត្តដោយសេចក្តីស្រឡាញ់ដែលយើងម្នាក់ៗពុំអាចយល់បាន ។ វាតម្រូវឲ្យមានអង្គដែលគ្មានអំពើបាប ដែលមានព្រះចេស្ដាជានិរន្តរលើជាតុទាំងឡាយ—សូម្បីតែសេចក្ដីស្លាប់ ជាអង្គដែលមានសមត្ថភាពគ្មានដែនកំណត់ដើម្បីរងទុក្ខនូវលទ្ធផលនៃរាល់អំពើបាប និងជំងឺរបស់យើង ហើយជាអង្គដែលយាងចុះក្រោមគ្រប់ទាំងអស់ [ សូមមើល គោលលទ្ធិ និង សេចក្ដីសញ្ញា ៨៨:៦ ] ។ នេះគឺជាបេសកកម្មរបស់ព្រះយេស៊ូវគ្រីស្ទ—នេះគឺជាដង្វាយធួនរបស់ទ្រង់ ។

ចុះតើគោលបំណងរបស់វាគឺជាអ្វី ? វាគឺដើម្បីធ្វើឲ្យយើងអាចត្រឡប់ទៅវត្តមានរបស់ព្រះវិញ ប្រែក្លាយកាន់តែដូចជាទ្រង់ ហើយមានអំណរដ៏ពេញលេញមួយ ។

ការណ៍នេះអាចសម្រេចបានតាមរយៈការយកឈ្នះលើឧបសគ្គបួនយ៉ាង ៖

១. សេចក្ដីស្លាប់ខាងរូបកាយ

២. សេចក្ដីស្លាប់ខាងវិញ្ញាណ ដែលកើតមានដោយសារអ័ដាម និងដោយសារអំពើបាបរបស់យើង

៣. ទុក្ខវេទនា និងជំងឺរបស់យើង

៤. ភាពទន់ខ្សោយ និងភាពពុំល្អឥតខ្ចោះរបស់យើង

( ថាត អរ ខាលីស្ទើរ « ដង្វាយធួនរបស់ព្រះយេស៊ូវគ្រីស្ទ » *Ensign* ឬ *Liahona* ខែ ឧសភា ឆ្នាំ ២០១៩ ទំព័រ ៨៥ )

សាសនាចក្រនៃ
ព្រះយេស៊ូវគ្រីស្ទ
នៃពួកបរិសុទ្ធថ្ងៃចុងក្រោយ

© ២០២២ by Intellectual Reserve, Inc. All rights reserved. កំណែ ៖ ២/២១ ។ ការបកប្រែនៃ *The Savior’s Atonement* ។
Cambodian ។ PD60012661 258. Printed in the United States of America.